World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៨៤

របាយការណ៍គិតត្រឹមថ្ងៃទី ៤ ខែមេសា ឆ្នាំ២០២២ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេបសំខាន់ៗ (ថ្ងៃទី២១ មីនា ដល់ថ្ងៃ ៣ មេសា ឆ្នាំ២០២២)

- ករណីវិជ្ជមានវីរុសកូវីដ-១៩ថ្មី បញ្ជាក់ដោយ PCR សរុបចំនួន ៦៩៧ និងករណីស្លាប់ថ្មីដោយសារជំងឺកូវីដ-១៩ចំនួន ២ ត្រូវបានរាយការណ៍នៅក្នុងរយៈពេល១៤ថ្ងៃចុងក្រោយនេះ។ ក្នុងចំណោមករណីនោះ ៦៧៩ករណី ឬ ៩៧ភាគរយជាករណីឆ្លងក្នុងសហគមន៍ ហើយ ១៨ករណី ឬ ៣ភាគរយជាករណីនាំ ចូលពីក្រៅប្រទេស។ ចំនួនករណីឆ្លងថ្មីបានធ្លាក់ចុះចំនួន ៧១ភាគរយ និងករណីស្លាប់បានធ្លាក់ចុះចំនួន ៨០ ភាគរយ បើធៀបទៅនឹងរយៈពេល១៤ថ្ងៃកន្លងទៅ។
- ករណីសរុបទាំងអស់ចំនួន ១៣៥.៧៨២ ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ៣.០៥៤ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០មក។ ក្នុងចំណោមនោះ ១៣២.២០១ ករណីបានជាសះស្បើយ។
- គិតត្រឹមថ្ងៃទី ៤ ខែមេសា ឆ្នាំ២០២២ តេស្តសរុបចំនួន ២.៦០១.៣៥២ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍ (RT-PCR)។ គិតចាប់តាំងពីខែមករា ឆ្នាំ ២០២០មក បុគ្គលសរុបចំនួន ១.៨៥៧.៩៨២ នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Reverse-Transcriptase Polymerase Chain Reaction, RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ៥.២ ភាគរយ។
- ចំនួនករណីឆ្លងវីរុសកូវីដ-១៩ថ្មីដែលត្រូវបានរាយការណ៍ បន្តធ្លាក់ចុះជាបន្តបន្ទាប់នៅក្នុងរយៈពេលពីរសប្តាហ៍កន្លងមកនេះ។ សមត្ថភាពថែទាំសុខភាពនៅតែមានស្ថេរភាពជាមួយនឹងករណីជំងឺកូវីដ-១៩ភាគច្រើនកំពុងទទួលការថែទាំ និងសះស្បើយនៅតាមផ្ទះ។
- ការកែសម្រួលវិធានការសុខាភិបាល និងសង្គមដើម្បីទប់ស្កាត់កុំឱ្យមានការចម្លងទ្រង់ទ្រាយធំ ការពង្រឹងការផ្តល់សេវាសុខភាព និងពន្លឿនការចាក់វ៉ាក់សាំងសម្រាប់ក្រុមប្រជាជនដែលងាយរងគ្រោះ នៅតែជាផ្នែកអាទិភាពដើម្បីគ្រប់គ្រងកូវីដ-១៩ និងបញ្ហាផ្សេងៗនាពេលអនាគតប្រកបដោយនិរន្តរភាព។

## ការរកឃើញបានឆាប់ និងឆ្លើយតបចំគោលដៅ

- **ការតាមដានជំងឺ:**
  - អង្គការសុខភាពពិភពលោក កំពុងតែផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាល លើការតាមដានពហុប្រភព ការវាយតម្លៃហានិភ័យ និងការកែសម្រួលវិធានការសុខាភិបាល និងសង្គមឡើងវិញ។
  - អង្គការសុខភាពពិភពលោក កំពុងផ្តល់ការប្រឹក្សាផ្នែកបច្ចេកទេសដល់ការបង្កើតប្រព័ន្ធតាមដានលំដាប់ហ្សែនវិភាគរកប្រភេទនៃមេរោគបំប្លែងថ្មី រួមទាំងពិនិត្យឡើងវិញនូវសមត្ថភាពថែទាំសុខភាព និងប្រព័ន្ធសុខាភិបាលនាពេលបច្ចុប្បន្ន។
  - អង្គការសុខភាពពិភពលោក កំពុងរៀបចំផែនការជាមួយក្រសួងសុខាភិបាល ដើម្បីធ្វើការពិនិត្យឡើងវិញនូវប្រព័ន្ធតាមដានជំងឺផ្តាសាយនៅកម្ពុជា ដោយប្រើប្រាស់លើការពង្រីកសមត្ថភាពសម្រាប់ការឆ្លើយតបនឹងជំងឺកូវីដ-១៩ និងការទស្សន៍ទាយអនាគតនៃការតាមដានជំងឺផ្លូវដង្ហើម ដើម្បីពង្រឹងការត្រៀមលក្ខណៈ និងការរកឃើញទាន់ពេលវេលា។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## វិធានការសុខភាពសាធារណៈ និងសង្គម

- ចាប់ពីថ្ងៃទី ២៨ ខែមីនា ដល់ថ្ងៃទី ១ ខែមេសា នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក បានរៀបចំវគ្គសិក្ខាសាលាចំនួនពីរនៅខេត្តបាត់ដំបង និងខេត្តសៀមរាប ដើម្បីពង្រឹង ប្រព័ន្ធតាមដាន ការអនុវត្តវិធានការសុខាភិបាល និងសង្គម។ ខេត្តចំនួន១០ផ្សេងទៀតបានចូលរួមសិក្ខាសាលាជាមួយតំណាងពីក្រសួងសុខាភិបាល រដ្ឋបាលខេត្ត មន្ទីរសុខាភិបាល មន្ទីរទេសចរណ៍ មន្ទីរធម្មការ និងសាសនា និងមន្ទីរអប់រំ។ សិក្ខាសាលាបានពិភាក្សាអំពីប្រព័ន្ធដែលមានស្រាប់ សម្រាប់វិស័យនីមួយៗ ដើម្បីសិក្សានិងកែសម្រួលវិធានការសុខាភិបាល និងសង្គម ដោយប្រើវិធីសាស្ត្រផ្អែកលើហានិភ័យ។ ជាជំហានបន្ទាប់ ការបង្កើតទំនាក់ទំនង និងការសម្របសម្រួលរវាងវិស័យនានា ដើម្បីកែសម្រួលវិធានការរួម ចាំបាច់ត្រូវស្វែងយល់បន្ថែម។

## ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍

- នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលបន្តអនុវត្តផែនការផ្សព្វផ្សាយពត៌មានសង្គមនៅក្នុងកំឡុងពេលចូលឆ្នាំប្រពៃណីខ្មែរ និងជំរុញដៃគូដែលធ្វើការងារក្នុងវិស័យសុខាភិបាល ស្ថាបន័ពាក់ពន្ធ័ និងអជ្ញាធរមូលដ្ឋានទាំងអស់ ដើម្បីបន្តការយកចិត្តទុកដាក់ប្រុងប្រយត្ន័ និងផ្សព្វផ្សាយការអនុវត្តវិធានការការពារដែលមានសុវត្ថិភាព ចំពោះក្រុមគ្រួសារ និងការការពារប្រជាជនដែលងាយរងគ្រោះ ដូចជាមនុស្សចាស់ជរា និងស្ត្រីមានផ្ទៃពោះ ដោយឲ្យពួកគេទៅចាក់វ៉ាក់សាំងកូវិត-១៩ មុនចូលឆ្នាំប្រពៃណីខ្មែរ។
- មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាពដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោកនឹងផ្តួចផ្តើមការអនុវត្តសកម្មភាព “ ការចូលរួមរបស់សហគមន៍ និងការតាមដានដោយមានការចូលរួមរបស់ហគមន៍ចំពោះជំងឺកូវីដ-១៩ ជំងឺផ្តាសាយ និង មេរោគផ្លូវដង្ហើមផ្សេងៗ ” រួមទាំងអនុវត្តសកម្មភាពបង្កើនសមត្ថភាពដល់បុគ្គលិកមន្ទីរសុខាភិបាលខេត្ត  ស្រុកប្រត្តិបត្តិ និងបុគ្គលិកមណ្ឌលសុខភាពនៅក្នុងខេត្តចំនួន ៩ នៅក្នុងប្រទេសកម្ពុជា ចាប់ពីខែ មេសា ឆ្នាំ ២០២២ នេះ។
- ក្រសួងសុខាភិបាលបានអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីកូវីដ-១៩ កាលពីថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២២ ដើម្បីផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងក្រោមប្រធានបទ  “ វីរុសកូវីដ-១៩បំប្លែងថ្មីអូមីក្រុង ឆ្លងលឿនខ្លាំងជាងវីរុសផ្សេងទៀត និងបណ្តាលឲ្យមានហានិភ័យធ្ងន់ធ្ងរ ចំពោះអ្នកនិងក្រុមគ្រួសារអ្នក ” ។  យុទ្ធនាការផ្តោតលើការលើកកម្ពស់ការយល់ដឹង និងការបង្កើនការចូលរួមរបស់បុគ្គលម្នាក់ៗ  ក្រុមគ្រួសារ និងសហគមន៍  ក៏ដូចជាស្ថាប័ន និងក្រសួងនានា អង្គការក្រៅរដ្ឋាភិបាល  និងអជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់  អង្គការជាតិ និងអន្តរជាតិ និងវិស័យឯកជនដើម្បីបន្តអនុវត្តវិធានការចាំបាច់ចំពោះជំងឺកូវីដ-១៩។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

- អង្គការ GAVI រួមជាមួយ អង្គការសុខភាពពិភពលោក (WHO) អង្គការ UNICEF និង អង្គការ CHAI នៅកម្ពុជា បានជួបជួបសម្តែងការគួរសមជាមួយ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) និងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងវិស័យសុខាភិបាល ជាពិសេសអំពីផែនការយុទ្ធសាស្ត្រចាក់វ៉ាក់សាំងនៅកម្ពុជា។ ក្នុងកិច្ចប្រជុំនោះ GAVI បានជូនដំណឹងថា COVAX នឹងបង្កើនការផ្តល់វ៉ាក់សាំង COVID-19 ដល់កម្ពុជារហូតដល់ ៣0% នៃចំនួនប្រជាជនសរុប។
- នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០២២ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) បានចេញលិខិតជាផ្លូវការជូនដំណឹងទៅដល់រាជធានី-ខេត្តទាំ២៥ ទាំអស់ដូចខាងក្រោម៖
  - ❖ វ៉ាក់សាំង Pfizer ប្រើប្រាស់សម្រាប់ដូសទី៤ចំពោះមនុស្សដែលមានអាយុ១៨ឆ្នាំ និងលើស
  - ❖ វ៉ាក់សាំង Pfizer ប្រើប្រាស់ដូសទី៣សសម្រាប់មនុស្សដែលមានអាយុពី១២ ទៅដល់១៧ឆ្នាំ



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩  ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

    - ផ្អាកការប្រើប្រាស់វ៉ាក់សាំង Sinopharm និង Sinovac សម្រាប់ការចាក់ដូសទី៣និងទី៤ ចំពោះមនុស្សដែលមានអាយុលើសពី១៨ឆ្នាំ រហូតដល់វ៉ាក់សាំងដែលមានកាលបរិច្ឆេទផុតកំណត់ខ្លីជាងត្រូវបានប្រើប្រាស់អស់។

- ដូសទីបី (ដូសជំរុញ) សម្រាប់កុមារអាយុ ៥ ឆ្នាំបានចាប់ផ្តើមអនុវត្តនៅថ្ងៃទី៣០ខែមីនា ឆ្នាំ២០២២ ដោយប្រើវ៉ាក់សាំង Sinovac ។
- ការគាំទ្ររបស់អង្គការសុខភាពពិភពលោកដល់កម្មវិធីជាតិផ្តល់ថ្នាំបង្ការៈ
    - កំណត់អត្តសញ្ញាណប្រជាជនដែលមិនទាន់បានចាក់វ៉ាក់សាំង និងធ្វើផែនការកម្រិតថ្នាក់ក្រោមជាតិ និងការអនុវត្តនៅតាមទីតាំងចាក់វ៉ាក់សាំង និងក្រុមការងារចុះចាក់វ៉ាក់សាំងចល័តទៅដល់សហគមន៍ដែលពិបាកចូលទៅដល់ ការប្រាស្រ័យទាក់ទង និងការចូលរួមរបស់សហគមន៍ ការតាមដាន និងត្រួតពិនិត្យនៅតាមមូលដ្ឋាន នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីចូលទៅដល់ក្រុមប្រជាជនកម្ពុជាដែលពិបាកចូលទៅដល់។
    - បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ដើម្បីចាក់វ៉ាក់សាំងដល់ភូមិជុំវិញបឹងទន្លេសាប និងភូមិដាច់ស្រយាលដទៃទៀតដែលមិនទាន់បានទទួលវ៉ាក់សាំង។

## អន្តរាគមន៍ និងការផ្តល់សេវាសុខភាព

- កិច្ចពិភាក្សាអំពីករណីសិក្សាចំនួនពីរវគ្គត្រូវបានរៀបចំឡើងតាមប្រព័ន្ធហ្ស៊ូមៈ ការបង្ហាញករណី សិក្សាមួយត្រូវបានបង្ហាញដោយខេត្តពោធិ៍សាត់ នៅថ្ងៃទី២២ខែមីនា និងការបង្ហាញករណីសិក្សា ចំនួនពីរករណីទៀតត្រូវបានបង្ហាញដោយខេត្តឧត្តរមានជ័យ និងដោយមន្ទីរពេទ្យមេគង្គកំពង់ចាមក្នុងថ្ងៃតែមួយ គឺថ្ងៃទី២៩ខែមីនាកន្លងទៅនេះ។
- ការបង្ហាត់បង្ហាញផ្ទាល់ពីវិធីព្យាបាលដោយប្រើម៉ាស៊ីនជំនួយដង្ហើម ត្រូវបានបញ្ចប់ទៅនៅមន្ទីរ ពេទ្យបង្អែកស្រុកចំនួន៣៦ ក្នុងខេត្តចំនួន៦ ក្នុងអំឡុងត្រីមាសទីមួយនៃឆ្នាំ២០២២នេះ។ យ៉ាងហោចណាស់មានបុគ្គលិកសុខាភិបាលចំនួន១០នាក់មកពីមន្ទីរពេទ្យនីមួយៗ បានចូលរួមក្នុង វគ្គ បង្ហាត់បង្ហាញដោយផ្ទាល់នេះ។ សកម្មភាពនេះ នឹងត្រូវធ្វើបន្តទៀតនៅក្នុងត្រីមាសទី២ ឆ្នាំ២០២២ នៅឯមន្ទីរពេទ្យបង្អែកស្រុកចំនួន៣៦ផ្សេងទៀត នៃខេត្តចំនួន៦ខេត្តផ្សេងទៀតដែរ។
- អង្គការសុខភាពពិភពលោក កំពុងធ្វើការសហការជាមួយនឹងក្រសួងសុខាភិបាល ដើម្បីពង្រឹង ការព្យាបាល ថែទាំអ្នកជំងឺកូវីដ-១៩នៅតាមផ្ទះ និងតាមដានជំងឺនៅតាមមន្ទីរពេទ្យ ដើម្បីបញ្ចៀស នូវបញ្ហាលើសពីសមត្ថភាពផ្តល់ការថែទាំព្យាបាល ដោយរួមបញ្ចូលទាំងការពិនិត្យឡើងវិញនូវឯកសារសម្រាប់ការប្រាស្រ័យទាក់ទង និងគោលការណ៍ណែនាំ។ ការស្ទង់មតិដ៏ឆាប់រហ័សមួយ ស្តីអំពីការថែទាំ និងការព្យាបាលតាមផ្ទះ ត្រូវបានធ្វើឡើងនៅខេត្តសៀមរាប កំពង់ចាម ព្រៃវែង កណ្តាល និងរាជធានីភ្នំពេញ។ លទ្ធផលដែលបានរកឃើញពីការស្ទង់មតិនេះ នឹងត្រូវប្រើដើម្បី ធ្វើ ការពិនិត្យឡើងវិញនូវនីតិប្រតិបត្តិស្តង់ដាសម្រាប់ប្រព័ន្ធនៃការថែទាំ និងព្យាបាលតាមផ្ទះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- យោងតាមលិខិតចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ដែលបានណែនាំដល់ថ្នាក់ដឹកនាំផ្នែកសុខាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យមានការធ្វើសមាហរណ័កម្មសេវាព្យាបាលជំងឺកូវីដ-១៩ ចូលទៅក្នុងប្រព័ន្ធសុខាភិបាលតែមួយ សម្រាប់មូលដ្ឋានសុខាភិបាលទាំងសាធារណ: និងឯកជននោះ អង្គការសុខភាពពិភពលោក បានជួយគូសពង្រាងនូវ ចរន្តអ្នកជំងឺបែបថ្មីមួយ សម្រាប់នាយកដ្ឋានមន្ទីរពេទ្យ ហើយក៏កំពុងតែជួយពង្រាងនូវនីតិប្រតិបត្តិ ស្តង់ដាសម្រាប់អនុវត្តតាមលិខិតរបស់ក្រសួងសុខាភិបាលនេះផងដែរ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## អេពីដេមីសាស្ត្រ

**ក្រាហ្វិកទី១. ខ្សែកោងអេពីដេមិកនៃករណីជំងឺកូវីដ-១៩ បញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ ២០២១-២០២២***




*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ។ ការតម្រូវធ្វើតេស្តសម្រាប់អ្នកដំណើរដែលចូលមកកម្ពុជាត្រូវបានលុបចោលចាប់តាំងពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២២

## តារាងទី១. តារាងសង្ខេបអំពីសូចនាករកូវីដ-១៩

| បច្ចុប្បន្នភាពអេពីដេមីសាស្ត្រ អំពីកូវីដ-១៩ | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
|---|---|---|---|---|
| | 12,841<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល១៤ថ្ងៃចុងក្រោយ | 679<br>ករណីវិជ្ជមានថ្មីក្នុងពេល១៤ថ្ងៃចុងក្រោយ | 2<br>ករណីស្លាប់ក្នុងពេល១៤ថ្ងៃចុងក្រោយ | 18<br>ករណីនាំចូលក្នុងពេល១៤ថ្ងៃចុងក្រោយ |
| | 2,601,352<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 135,782<br>ករណីសរុប | 3,054<br>ករណីស្លាប់សរុប | |

| | | | |
|---|---|---|---|
| ការផ្តល់សេវាសុខភាព អំពីកូវីដ-១៩ | 79<br>ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | 145<br>ចំនួនមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ | 1,626<br>ចំនួនគ្រែអ្នកជំងឺធ្ងន់ដែលមាននៅមន្ទីរពេទ្យ និង មណ្ឌលព្យាបាល |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## តារាងទី២. ការវាយតម្លៃ[1]អំពីដំណាក់កាលចម្លងតាមខេត្តនីមួយៗ

| ដំណាក់កាលចម្លង | ខេត្ត |
|---|---|
| ដំណាក់កាលចម្លងទី៣៖ ការឆ្លងក្នុងសហគមន៍ទ្រង់ទ្រាយធំ | រាជធានីភ្នំពេញ |
| ដំណាក់កាលចម្លងទី២៖ ការឆ្លងក្នុងសហគមន៍តាមតំបន់ | ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកណ្ដាល ខេត្តតាកែវ ខេត្តកំពត ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តព្រះវិហារ ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តកោះកុង ខេត្តកែប ខេត្តក្រចេះ និងខេត្តប៉ៃលិន |
| ដំណាក់កាលចម្លងទី១៖ ករណីនាំចូល | ខេត្តពោធិសាត់ ខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី * |

** ភស្តុតាងមានកម្រិតសម្រាប់ការចាត់ថ្នាក់ឡើងវិញ ប៉ុន្តែទំនងជាស្ថិតក្នុងដំណាក់កាលទី ២*

## តារាងទី៣. យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩តាមក្រុមគោលដៅ (បុគ្គលិកសុខាភិបាល មនុស្សចាស់ មនុស្សពេញ វ័យ និងកុមារ)

<table>
<tr><th rowspan="3">ចាប់ផ្ដើម</th><th rowspan="2">បុគ្គលិកសុខាភិបាល</th><th colspan="2">មនុស្សពេញវ័យ</th><th></th><th colspan="3">យុវវ័យ និងកុមារ</th></tr>
<tr><th>អាយុចាប់ពី ៦០ឆ្នាំ</th><th>អាយុចាប់ពី ១៨ឆ្នាំ</th><th>អាយុ៣-៤ ឆ្នាំ</th><th>អាយុ៥ឆ្នាំ</th><th>អាយុពី៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ</th><th>អាយុចាប់១២ ឆ្នាំដល់ក្រោម ១៨ឆ្នាំ</th></tr>
<tr><th>(N=43,646)<br>10 កុម្ភៈ 2021</th><th>(N=1,378,688)<br>10 កុម្ភៈ 2021</th><th>(N=10,000,000)<br>10 កុម្ភៈ2021</th><th>(N=610,730)<br>22 កុម្ភៈ 2022</th><th>(N=304,317)<br>1 វិច្ឆិកា 2021</th><th>(N=1,897,382)<br>17 កញ្ញា 2021</th><th>(N=1,827,348)<br>1 សីហា 2021</th></tr>
<tr><td>ដូសទី១</td><td>43,646<br>(100%)</td><td>1,410,188<br>(102.3%)</td><td>10,268,201<br>(102.7%)</td><td>309,547<br>(50.7%)</td><td>376,761<br>(123.8%)</td><td>2,044,671<br>(107.8%)</td><td>1,829,898<br>(100.1%)</td></tr>
<tr><td>ដូសទី២</td><td>43,646<br>(100%)</td><td>1,394,086<br>(101.1%)</td><td>9,922,773<br>(99.2%)</td><td>93,612<br>(15.3%)</td><td>290,765<br>(95.5%)</td><td>1,970,881<br>(103.9%)</td><td>1,764,428<br>(96.6%)</td></tr>
<tr><td>ដូសទី៣</td><td>43,646<br>(100%)</td><td>863,989<br>(62.7%)</td><td>5,907,671<br>(59.1%)</td><td>N/A</td><td>635<br>(0.2%)</td><td>853,498<br>(45.0%)</td><td>1,210,729<br>(66.3%)</td></tr>
<tr><td>ដូសទី៤</td><td colspan="3">1,183,539<br>(11.8 %)</td><td>N/A</td><td>N/A</td><td>N/A</td><td>N/A</td></tr>
</table>

[1] តំណាក់កាលចម្លងសម្រាប់ការចាត់ថ្នាក់កម្រិតថ្នាក់ក្រោមជាតិដោយអង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី៤. អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស តាមប្រភេទវ៉ាក់សាំងកូវីដ-១៩**

| ប្រភេទវ៉ាក់សាំង កូវីដ-១៩ | **Sinovac** | Sinopharm | AstraZeneca (Covishield) | **Janssen** (Ad26.COV2-S) | **AstraZeneca** (Vaxzevria) | **Moderna** (Spikevax) | **Pfizer** BioNTech (Comirnary) | **សរុប** |
|---|---|---|---|---|---|---|---|---|
| ចំនួនករណី | 101 | 79 | 29 | 4 | 1 | 3 | 0 | **217** |
| ចំនួនដូសសរុបបានចាក់ | 24,084,168 | 7,466,841 | 323,344 | 1,053,151 | 2,725,906 | 349,239 | 971,809 | **36,974,458** |
| អត្រានៃហេតុការណ៍ក្នុងចំណោម ១០០.០០០ដូស | 0.42 | 1.06 | 8.97 | 0.38 | 0.04 | 0.86 | 0 | **0.59** |

## ឯកសារយោង និងតំណរភ្ជាប់ដែលពាក់ព័ន្ធ

- គេហទំព័រក្រសួងសុខាភិបាល: គេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល
- របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក: របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់ប្រទេសកម្ពុជា។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់តំបន់:របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់សាកល: របាយការណ៍បច្ចុប្បន្នភាពស្តីពីកូវីដ-១៩ផ្នែកប្រតិបត្តិការ និងអេពីដេមីសាស្ត្ររបស់អង្គការសុខភាពពិភពលោកថ្នាក់សាកល។
- គោលការណែនាំរបស់អង្គការសុខភាពពិភពលោក: គោលការណែនាំសម្រាប់ប្រទេស និងបច្ចេកទេសអំពីកូវីដ-១៩ចុងក្រោយបំផុតរបស់អង្គការសុខភាពពិភពលោក។
- ក្តារព័ត៌មានឌីជីថលស្តីពីកូវីដ-១៩របស់អង្គការសុខភាពពិភពលោក: ទិន្នន័យកូវីដ-១៩កម្រិតតំបន់ និងពិភពលោកចុងក្រោយបំផុត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។